April 18, 2019

# តំណាងរាស្ត្របក្សប្រឆាំងអូស្ត្រាលី ប្ដេជ្ញាបង្កើតច្បាប់ដាក់សម្ពាធរបបលោក ហ៊ុន សែន ឲ្យងាកមកស្ដារប្រជាធិបតេយ្យ និងសិទ្ធិមនុស្សឡើងវិញ



លោក ជូលៀន ហ៊ីល (Julian Hill) សមាជិកសភាអូស្ត្រាលីថ្លែងក្នុងកិច្ចប្រជុំសភា ថ្កោលទោសការបោះឆ្នោតក្លែងក្លាយនៅកម្ពុជា ហើយទាមទារឲ្យដាក់ទណ្ឌកម្មគ្រួសារ ហ៊ុន។ រូប៖ ហ្វេសប៊ុក

**ដោយ មាន ឫទ្ធិ** RFA 2019-04-15

តំណាងរាស្ត្រអូស្ត្រាលីមកពីគណបក្សការងារ ដែលជាគណបក្សប្រឆាំង លោក ជូលៀន ហ៊ីល (Julian Hill) ប្ដេជ្ញាបង្កើតច្បាប់ដាក់សម្ពាធរបបលោក ហ៊ុន សែន ឲ្យងាកមកស្ដារប្រជាធិបតេយ្យ និងសិទ្ធិមនុស្សឡើងវិញ ស្របតាមកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស ប្រសិនបើគណបក្សការងាររបស់លោក ឈ្នះការបោះឆ្នោតជាតិខាងមុខ។ ការប្ដេជ្ញាចិត្តនេះ ធ្វើឡើងស្របពេលដែលប្រទេសអូស្ត្រាលី នឹងរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងនាយករដ្ឋមន្ត្រីសម្រាប់អាណត្តិថ្មី ដែលនឹងប្រព្រឹត្តិទៅនៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៩ ខាងមុខ។

ក្រៅពីបានថ្លែងសារជូនពរប្រជាពលរដ្ឋខ្មែរអូស្ត្រាលី និងពលរដ្ឋខ្មែរទូទៅ ក្នុងឱកាសទិវាបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិនេះ លោក ជូលៀន ហ៊ីល មានប្រសាសន៍ថា គណបក្សការងាររបស់លោក តែងតែធ្វើការ ដើម្បីទាមទារឲ្យមានសន្តិភាព និងប្រជាធិបតេយ្យនៅកម្ពុជា។ លោកថា ក្រោមការដឹកនាំរបស់គណបក្សការងារ កាលពីឆ្នាំ១៩៩១ ដែលកាលណោះមានលោក ហ្គារ៉េត អេវ៉ាន (Gareth Evans) ជារដ្ឋមន្ត្រីការបរទេស ប្រទេសអូស្ត្រាលី បានផ្តួចផ្តើមឲ្យមានកិច្ចព្រមព្រៀងសន្តិភាពនៅកម្ពុជា។ លោក ជូលៀន ហ៊ីល សង្កត់ធ្ងន់ៗ ថា ក៏ប៉ុន្តែ បច្ចុប្បន្ននេះ កិច្ចសន្យានានា ដូចដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ ពុំទាន់សម្រេចបាននៅឡើយទេ ដោយកម្ពុជាអាចមានសន្តិភាពច្រើនជាងកាលពីពេលមុន តែគ្មានលទ្ធិប្រជាធិបតេយ្យនោះទេ៖ «ប្រសិនបើគណបក្សយើងឈ្នះឆ្នោត ខ្ញុំ និងតំណាងរាស្ត្រដទៃទៀតរបស់យើងនឹងលើកយកមកនិយាយឲ្យបានផុលផុសក្នុងរដ្ឋសភាជាតិ ដើម្បីដាក់សម្ពាធកាន់តែខ្លាំងជាងនេះ មកលើរបបលោក ហ៊ុន សែន ក្រោមរូបភាពជាបម្រាមទិដ្ឋាការ ការបង្កកទ្រព្យសម្បត្តិ និងធ្វើការងារផ្សេងៗ ទៀត ដើម្បីផ្ញើសារប្រាប់ទៅរដ្ឋាភិបាលកម្ពុជាថា អ្នកឯងមិនត្រូវធ្វើឲ្យពលរដ្ឋខ្លួនឯងរស់នៅក្នុងសភាពភ័យខ្លាចនោះទេ។ អ្នកត្រូវចាត់ទុកពលរដ្ឋខ្លួនឯងឲ្យបានត្រឹមត្រូវ និងប្រកបដោយការគោរពសិទ្ធិមនុស្ស។ នេះគឺជាអ្វី ដែលយើងក្នុងនាមជាមិត្ត និងអ្នកជិតខាង រំពឹងចង់បានពីរបបគ្រប់គ្រងរបស់លោក ហ៊ុន សែន ឲ្យមានការប្តេជ្ញាចិត្តគោរពសិទ្ធិមនុស្ស»។

លោក ជូលៀន ហ៊ីល បន្តថា ក្រៅពីបញ្ហាសំខាន់ៗ ទាំងនេះ សម្រាប់ពលរដ្ឋខ្មែរអូស្ត្រាលី បញ្ហាដទៃទៀតដែលសំខាន់ដូចគ្នាសម្រាប់ពលរដ្ឋអូស្ត្រាលីជារួម ជាគោលនយោបាយរបស់គណបក្សការងារ រួមមាន ការរួមគ្នាបង្កើតប្រទេសអូស្ត្រាលីមួយ មានភាពយុត្តិធម៌ប្រសើរជាងមុន ការវិនិយោគលើមន្ទីរពេទ្យ សាលារៀន សេវាដឹកជញ្ជូន ហេដ្ឋារចនាសម្ព័ន្ធ និងការកាត់បន្ថយគម្លាតពន្ធដារសម្រាប់ពលរដ្ឋអូស្ត្រាលី ដែលជាអ្នកធ្វើការ។

គណបក្សការងាររបស់អូស្ត្រាលី បច្ចុប្បន្ន ដឹកនាំដោយលោក ប៊ីល សតថែន (Bill Shorten)។ គណបក្សនេះ ក្លាយជាគណបក្សប្រឆាំងក្នុងរដ្ឋាភិបាលសហព័ន្ធអូស្ត្រាលី ចាប់តាំងពីឆ្នាំ២០១៣ មក។ ការបោះឆ្នោតជាតិអូស្ត្រាលី ថ្ងៃទី១៨ ខែឧសភាខាងមុខនេះ គឺជាការបោះឆ្នោតជ្រើសតាំងអាណត្តិតំណាងរាស្ត្រ និងសមាជិកព្រឹទ្ធសភាអូស្ត្រាលី លើកទី៤៦ ក្រោយពីមានការរម្លាយរដ្ឋសភាអាណត្តិចាស់មក៕